គណៈកម្មាធិការដើម្បីសិទ្ធិបោះឆ្នោតរបស់ខ្មែរនៅក្រៅប្រទេស

**COMMITTEE FOR ELECTION RIGHTS OF OVERSEAS CAMBODIANS (THE CEROC)**

**Email: board@khmeroversea.info, www.khmeroversea.info**

# ប្រជាពលរដ្ឋខ្មែរដែលរស់នៅក្រៅប្រទេសត្រូវបានគេរំលោភសិទ្ធិចូលរួមបោះឆ្នោត អស់រយៈពេល២៥ឆ្នាំតាមស្មារតីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ២៣ តុលា ១៩៩១

សំរាប់ខួប២៥ឆ្នាំនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស២៣ តុលា ១៩៩១ - ២៣ តុលា ២០១៦ នេះ ប្រជាពលរដ្ឋខ្មែរដែលរស់នៅក្រៅប្រទេសត្រូវបានគេបំពានលើសិទ្ធិចូលរួមនយោបាយមួយគឺការចូលរួមបោះឆ្នោតនូវរាល់ការបោះឆ្នោតជាតិម្តងៗ។ នៅសម័យអ៊ុនតាក់ឆ្នាំ១៩៩៣ គណៈកម្មាធិការរៀបចំការបោះឆ្នោតនៅពេលនោះបានសំរួលដល់ប្រជាពលរដ្ឋខ្មែរដែលរស់នៅក្រៅប្រទេសបានចូលរួមបោះឆ្នោត។

តែចាប់ពីឆ្នាំ១៩៩៨មក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មីបានរំលោភសិទ្ធិចូលរួមនយោបាយគឺការចូលរួមបោះឆ្នោតរបស់ពលរដ្ឋខ្មែរនៅក្រៅប្រទេស ពីទីតាំងដែលខ្លួនកំពុងរស់នៅ កំពុងធ្វើការ និងកំពុងសិក្សារៀនសូត្រ។ ថ្វីត្បិតតែក្នុងកំឡុងពេលដែលមានការចុះឈ្មោះបោះឆ្នោតរវាងថ្ងៃទី១ ខែកញ្ញា ដល់ថ្ងៃទី៣០ ខែវិច្ឆិការ ឆ្នាំ២០១៦នេះ ពលរដ្ឋខ្មែរនៅក្រៅប្រទេសទាំងអស់គឺមានន័យថាទាំងពលករចំណាកស្រុក ទាំងសិស្សនិស្សិត មន្ត្រីរាជការ និងខ្មែរដែលរស់នៅអចិន្ត្រៃយ៍តាមបណ្តារប្រទេសជឿនលឿនទាំងឡាយមិនបានចូលរួមចុះឈ្មោះបោះឆ្នោតដោយងាយស្រួលឡើយ។ បើពួកគេចង់ចុះឈ្មោះគឺពួកគេត្រូវជិះយន្តហោះទៅស្រុកកំណើតរបស់ខ្លួន ដែលប្រការនេះមានការចំណាយយ៉ាងច្រើនទាំងពេលវេលា ទាំងធនធាន។

**ប្រការនេះគឺជាការរំលោភទៅលើស្មារតីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសយ៉ាងប្រត្យក្ស។**

អង្គការដឺស៊ីរ៉ក់សូមអំពាវនាវដល់រាជរដ្ឋាភិបាលក្រុងភ្នំពេញជួយសំរួលនិងអនុញ្ញាតអោយមានការចុះឈ្មោះបោះឆ្នោត និង ការបោះឆ្នោតនៅតាមបណ្តារទីតាំងនានាជុំវិញពិភពលោកដែលមានប្រជាពលរដ្ឋខ្មែររស់នៅកុះករដើម្បីគោរពអោយបានត្រឹមត្រូវតាមស្មារតីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

សូមអរព្រះគុណ និង សូមអរគុណ

ធ្វើនៅប្រទេសកាណាដា ថ្ងៃទី២៣ តុលា ២០១៦

គណៈក្រុមប្រឹក្សាគណៈកម្មាធិការដើម្បីសិទ្ធិបោះឆ្នោតរបស់ខ្មែរនៅក្រៅប្រទេស

Committee for Election Rights of Overseas Cambodians (The CEROC)
Contact: PO Box #554, 2949 – 17th Ave. SE, Calgary, AB T2A 0P7, Canada